# អង្គការ កិច្ចការខ្មែរបំរើព្រះគ្រីស្ទ

## Cambodian Ministries *for* Christ

អាសយដ្ឋាន: ភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ: ០១២ ៩១២ ២៧៨, អ៊ីម៉ែល: rmanickam2@cmcmission.org , គេហទំព័រ: www.cmcmission.org


## របាយការណ៍ស្តីពីការចែកស្បៀងអាហារឲ្យដល់ប្រជាពលរដ្ឋក្រីក្រ

កាលពីថ្ងៃទី២៥ខែសីហាឆ្នាំ២០២១កន្លងទៅនេះអង្គការ កិច្ចការខ្មែរបំរើព្រះគ្រីស្ទ បាននាំយកអំណោយជាស្បៀងអាហារ ទៅចែកជូនដល់ប្រជាពលរដ្ឋទាល់ក្រដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយកន្លងមកនិងផលប៉ះពាល់ពីជំងឺឆ្លងកាចសាហាវកំពុងរាតត្បាត ក៏ដូចជាគ្រួសារ ចាស់ជរា ជនពិការ ស្ត្រីមេម៉ាយ ដែលរស់នៅក្នុងភូមិអូស្វាយ ឃុំអូស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ គ្រួសារទាំងនោះមានចំនួនប្រាំដប់មួយគ្រួសារ ។





អំណោយទាំងអស់នោះបានមកពីថវិកាសប្បុរសធ៌មរបស់បងប្អូននិងគ្រួសារខ្មែរ និងមកពីព្រះវិហារនៅសហរដ្ឋអាមេរិក ។ ដែលមានចំនួនទឹកប្រាក់សរុបបីរយដុល្លាអាមេរិក ។

យើងក៏បានបែងចែកថវិកាទាំងនោះទិញជាស្បៀងអាហារសម្រាប់ចែកជូនដល់ដប់មួយគ្រួសារ



ដែលក្នុងមួយគ្រួសារៗទទួលបាន

១ អង្ករ ២៥គីឡូក្រាម

២ ទឹកត្រីមួយយួរស្មើ៦ដប

៣ ទឹកស៊ីអ៊ីវមួយយួរស្មើ៦ដប

៤ អំបិល២គីឡូក្រាម

៥ មីឆ្អិនស្រាប់មួយកេះស



៦ ត្រីខកំប៉ុងមួយយួរស្មើ១០កំប៉ុង

អង្គការ កិច្ចការខ្មែរបំរើព្រះគ្រីស្ទ និងក្រុមគ្រួសារដែលបានទទួលស្បៀងទាំងអស់សូមថ្លែងអំណរគុណដល់បងប្អូនទាំងអស់នៃព្រះវិហារនៅសហរដ្ឋអាមេរិកដែលបានផ្ញើជាជង្វាយមកដើម្បីជួយដល់ប្រជាជននិងអ្នកទាល់ក្រដែលកំពុងខ្វះខាតនិងត្រូវការនូវ



ស្បៀងអាហារសម្រាប់ដោះស្រាយប្រចាំថ្ងៃនៅក្នុងប្រទេសកម្ពុជាយើង ។ អំណោយជាស្បៀងអាហារទាំងអស់នេះគឺជាការផ្តល់នូវក្តីសង្ឃឹមដល់ប្រជាពលរដ្ឋរបស់យើង ហើយក៏ជាការដែលយើងបានដាក់ស្នាមញញឹមជាថ្មីសម្រាប់ពួកគាត់ទាំងអស់គ្នា ។ សំខាន់គឺបងប្អូនបានជួយផ្តល់ឲ្យប្រជាជនយើងនូវលទ្ធិភាពក្នុងការរស់នៅបន្តទៅមុខទៀតដោយក្តីស្រឡាញ់ ។



សូមអរគុណយ៉ាងជ្រាលជ្រៅអស់ពីដួងចិត្តចំពោះសេចក្តីស្រឡាញ់ដែលបងប្អូនទាំងអស់មានមកអំពីព្រះ យេស៊ូវគ្រីស្ទនៃយើង ។ យើងនៅតែបន្តសេចក្តីអធិស្ឋានទាំងនេះបន្ត ហើយសង្ឃឹមថាអស់លោកអ្នកបងប្អូននឹងនៅតែបន្តជួយផ្តល់ជាស្បៀងអាហារនិងរបស់ផ្សេងៗទៀតដើម្បីជួយដល់ប្រជាជនយើងដែលកំពុងជួបការលំបាកនៅក្នុងប្រទេសកម្ពុជានឹងទៅពេលអនាគតបន្តទៀត ។

សូមព្រះដ៏ជាព្រះនៃយើងបានប្រទានពរដល់អស់លោកអ្នកបងប្អូននិងម្ចាស់ជំនួយទាំងអស់ ។

---

**ម៉ានិភាម រ៉ាវី**